ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៥ លេខ ១២

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC



ក
ស
វ

# Work Activities

ប្រចាំខែធ្នូ ឆ្នាំ២០១២



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | លេខទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា៩ និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល | ១ |
| ២- | ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែតុលា ឆ្នាំ២០១២ | ៣ |
| ៣- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១០ |

## សេចក្តីព្រាងច្បាប់ស្តីពី

# វិសោធនកម្មមាត្រា៩និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល

កាលពីថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១២ វេលាម៉ោង៨:៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **តាំង គុនហ៊ាង** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌( ECOSOCC ) និង ឯកឧត្តម **ជីវ សុខហាក់** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា៩និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងរដ្ឋលេខាធិការមុខងារសាធារណៈ។

ក្រោយពីបានទទួលអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋលេខាធិការមុខងារសាធារណៈ និងក្រសួងមហាផ្ទៃ បានសហការរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ ដើម្បីសិក្សានិងរៀបចំលិខិតបទដ្ឋានពាក់ព័ន្ធនឹងការសុំច្បាប់ឈប់សម្រាករបស់មន្ត្រីរាជការស៊ីវិល នាថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១២។ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានចារឯកភាពលើស្មារតីនៃកិច្ចប្រជុំពិគ្រោះយោបល់នេះ នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ ២០១២ ។

ចំពោះមាត្រាទាំងពីរដែលត្រូវស្នើសុំធ្វើវិសោធនកម្មនេះ គឺមានពាក់ព័ន្ធនឹងផលប្រយោជន៍ចំពោះមន្ត្រីរាជការស៊ីវិល ដូចខាងក្រោម៖



- ការសុំអនុញ្ញាតច្បាប់ឈប់សម្រាក
- ការចូលនិវត្តន៍
- បៀវត្តមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្ស
- ប្រាក់បេសកកម្មក្នុងនិងក្រៅប្រទេស។ល។

កន្លងមកដោយយោងតាមការចាំបាច់និងបន្ទាន់ ដើម្បីឲ្យមាន

លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកិច្ចការខាងលើនិងសម្រាប់ការគ្រប់គ្រងមន្ត្រីរាជការ រាជរដ្ឋាភិបាល បានចេញលិខិតបទដ្ឋានគតិយុត្តមួយចំនួនដែលពាក់ព័ន្ធនឹងការសុំអនុញ្ញាតច្បាប់ឈប់ឬការឈប់សម្រាកប្រចាំឆ្នាំ ការសុំអនុញ្ញាតច្បាប់ឈប់របស់មន្ត្រីការទូត និងការចូលនិវត្តន៍របស់មន្ត្រីរាជការស៊ីវិល។

ក្នុងគោលបំណងរក្សាឲ្យនៅជាធរមាននូវលិខិតបទដ្ឋានគតិយុត្តមួយចំនួនដែលពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិលដែលមានស្រាប់ និងជាការបើកផ្លូវដល់ការកសាងលិខិតបទដ្ឋានគតិយុត្តមួយចំនួនបន្ថែមទៀតដែលពាក់ព័ន្ធនឹងខ្លឹមសារនៃមាត្រាដែលត្រូវស្នើសុំធ្វើវិសោធនកម្មនេះ រដ្ឋលេខាធិការមុខងារសាធារណៈបានរៀបចំសេចក្តីពាងច្បាប់ស្តីពីវិសោធនកម្មមាតា៩និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ហើយបានស្នើសុំឆ្លងតាមនីតិវិធីរបស់ទីស្តីការគណៈរដ្ឋមន្ត្រី(១)។



អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីពាងច្បាប់ស្តីពីវិសោធនកម្មមាត្រា៩ និងមាត្រា ១០ ដែលបានស្នើសុំឆ្លងនេះ ក្រោយពីបានពិភាក្សាផ្លាស់ប្តូរយោបល់គ្នាយ៉ាងផុលផុស អង្គប្រជុំបានសម្រេចកែសម្រួល ទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។ អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះទាំងស្រុង។

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា៩និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។

# ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែតុលា ឆ្នាំ២០១២*



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែតុលា ឆ្នាំ២០១២នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១២ ដែលដឹកនាំដោយឯកឧត្តម **យឹម ឈុំលឡា** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក-សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ នាខែតុលា ឆ្នាំ២០១២ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ថយចុះ ០,២% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ១,២% ធៀបនឹងខែដូចគ្នាឆ្នាំមុន(រយៈពេល១២ខែ)។ ការចុះថ្លៃទំនិញប្រើប្រាស់នាខែតុលាធៀបនឹងខែមុន ដោយមានការរួមចំណែកនៃក្រុមផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន ៧៧% ការដឹកជញ្ជូន ៤៣% និងភោជនីយដ្ឋាន ១០%។

**បើធៀបនឹងខែដូចគ្នាឆ្នាំមុន ក្រុមទំនិញនិងមុខទំនិញសំខាន់ៗមានបម្រែបម្រួលថ្លៃដូចខាងក្រោម**

| *ក្រុមទំនិញ:* | *មុខទំនិញ:* | |
|---|---|---|
| ម្ហូបអាហារ : +០,៦% | អង្ករ : +២,៧% | បន្លែ: +៦,២% |
| សម្លៀកបំពាក់ និងស្បែកជើង : +២,៩% | សាច់ជ្រូក : -១១,៥% | ឧស្ម័ន: +០,៩% |
| ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន : +២,១% | សាច់គោស្រស់: +១៥% | ប្រេងសាំង: +២,៩% |
| គ្រឿងសង្ហារិម និងសម្ភារៈប្រើប្រាស់ : +៣,៤% | សាច់មាន់ : -២,៧% | ប្រេងម៉ាស៊ូត: +៥,៣% ។ |
| ការដឹកជញ្ជូន: +១,០% | ត្រីស្រស់ : -០,៩% | |
| ភោជនីយដ្ឋាន: +៣,៥% | | |

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខនៃតារាងទាំង៥ទេ។ អ្នកប្រើប្រាស់ទិន្នន័យអាចទាញយកតួលេខពីតារាងតាមសេចក្តីត្រូវការរបស់ខ្លួន។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ ( Excel ) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

### តារាង១.បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១០–២០១២

| ឆ្នាំ | ធៀបនឹង... | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា[P] | ធ្នូ[P] | ប្រចាំឆ្នាំ[P] |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១២ | ខែដូចគ្នាឆ្នាំមុន | ៥,៨% | ៥,៤% | ៥,៤% | ៤,៨% | ២,២% | ១,៨% | ១,៣% | ២,២% | ១,៤% | ១,២% | ១,៥% | ១,៥% | ២,៨% |
| | ខែមុន | ១,០ | ០,៤ | ០,៦% | ០,៥% | -១,១% | ០,១% | ០ | ១,១% | ០,២% | -០,២% | -០,៣% | -០,៩% | |
| ២០១១ | ខែដូចគ្នាឆ្នាំមុន | ៣,៣% | ៣,៨% | ៣,៨% | ៥,២% | ៦,៥% | ៧,១% | ៧,១% | ៦,៤% | ៦,៧% | ៥,៣% | ៥,៦% | ៤,៩% | ៥,៥% |
| | ខែមុន | ០,២% | ០,៧% | ០,៧% | ១,១% | ១,៤% | ០,៥% | ០,៦% | ០,២% | ១,០% | ០,១% | -០,៧% | -០,៨% | |
| ២០១០ | ខែដូចគ្នាឆ្នាំមុន | ៦,៩% | ៧,៣% | ៦,៧% | ៥,៣% | ៤,៥% | ២,៥% | ១,៦% | ១,៧% | ១,៩% | ៣,៦% | ៣,២% | ៧,៣% | ៤% |
| | ខែមុន | ០% | ០,៣% | ០,៦% | -០,៣% | ០,២% | ០% | ០,៥% | ០,៩% | ០,៧% | ១,៤% | –១,០% | –០,២% | |

P: តួលេខខែ វិច្ឆិកា ធ្នូ និងប្រចាំឆ្នាំ២០១២ ជាតួលេខព្យាករដោយ ក.ស.វ. (តាមវិធីសាស្ត្រ DECOMPOSITION)

**ក្រាហ្វ ១. បម្រែបម្រួលថ្លៃទំនិញប្រើប្រាស់ឆ្នាំ២០១២ និង២០១១ (ធៀបនឹងខែដូចគ្នាឆ្នាំមុន)**

ក្រាហ្វបង្ហាញនិន្នាការបម្រែបម្រួលសន្ទស្សន៍ថ្លៃ (ធៀបនឹងខែដូចគ្នា) ឆ្នាំ ២០១២ និង ២០១១ និងអត្រាអតិផរណាព្យាករបីខែទៅមុខ (ធៀបនឹងខែដូចគ្នាឆ្នាំមុន) សម្រាប់ឆ្នាំ២០១២។




➡**អត្រាប្តូរប្រាក់៖**

| *ប្រភេទ* | អត្រាខែតុលា ២០១២ | អត្រាខែកញ្ញា ២០១២ | អត្រាខែតុលា ២០១១ | *ប្រភេទ* | អត្រាខែតុលា ២០១២ | អត្រាខែកញ្ញា ២០១២ | អត្រាខែតុលា ២០១១ |
|---|---|---|---|---|---|---|---|
| **៛/ដុល្លារ** | ៤០៣០៛/១$ | ៤០៤៣៛/១$ | ៤១០០៛/១$ | **បាត/ដុល្លារ** | ៣០,៧១បាត/១$ | ៣០,៨៦បាត/១$ | ៣០,៤៧បាត/១$ |
| **៛/បាត** | ១៣១៛/១បាត | ១៣១៛/១បាត | ១៣៤៛/១បាត | **ដុង/ដុល្លារ** | ២០៨៣០ដុង/១$ | ២០៨៦០ដុង/១$ | ២០៩៨៦ដុង/១$ |
| **៛/ដុង** | ០,១៩៣៛/១ដុង | ០,១៩៣៛/១ដុង | ០,១៩៥៛/១ដុង | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់រតនាគារជាតិ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារ ក្នុងខែតុលា ឆ្នាំ២០១២ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម៖

- *ចំណូលថវិកាជាតិអនុវត្តបានចំនួន ៥៨៣,៦ ពាន់លានរៀល (មធ្យមប្រចាំខែ ៧១% នៃគម្រោង) ក្នុងនោះ*ចំណូលចរន្តចំនួន ៥៦៤,៨ ពាន់លានរៀល (មធ្យមប្រចាំខែ ៩៩% នៃគម្រោង) និងចំណូលមូលធនចំនួន ១៨,៧ *ពាន់លានរៀល*។
- បើធៀបនឹងខែមុន**ចំណូលថវិកាជាតិ**ថយចុះ ៣% ប៉ុន្តែកើនឡើង ២១% *ធៀបនឹងខែដូចគ្នាឆ្នាំមុន* ។ ការថយចុះធៀបនឹងខែដូចគ្នាឆ្នាំមុន បណ្តាលមកពីចំណូលចរន្តថយចុះ ៤% ។
- នៅក្នុងចំណូលចរន្ត៖

**ក្រាហ្វ ២. ចំណូលថវិកាជាតិ ឆ្នាំ ២០១១ និង ២០១២**
(ពាន់លានរៀល)



- ✓ ចំណូលសារពើពន្ធមានចំនួន ៤៧៤,២ ពាន់លានរៀល ថយចុះ ៣% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ១៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន ។
- ✓ ចំណូលមិនមែនសារពើពន្ធមានចំនួន ៩០,៦ ពាន់លានរៀល ថយចុះ ១០% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៣៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

| **មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ** (ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | | **មុខចំណូលមួយចំនួនក្នុងចំណូលមិនមែនសារពើពន្ធ** (ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ : -២% | ( +១០%) | ➢ នេសាទ: -៤៩% | (-៩៧%) |
| ➢ ចំណូលពន្ធដារ : -៥% | (+៨%) | ➢ រុក្ខាប្រមាញ់ : +៣៤៣% | (-៣៦%) |
| ➢ ចំណូលសារពើពន្ធផ្សេងៗ: -២១% | (0) | ➢ អាកាសចរណ៍ស៊ីវិល : +៩០% | (+១០%) |
| ✧ កាស៊ីណូ : -២៩% | (-១៣%) | ➢ ផលទុនទេសចរណ៍: កើនគំហុក | (+១១៧%) |
| ✧ អាជ្ញាបណ្ណក្នុងស្រុក : -៧៦% | (-៧៣%) | ➢ ប្រៃសណីយ៍ និងទូរគមនាគមន៍ : +៣% | (-៣%) |
| ✧ កម្រៃគ្រប់គ្រងនិងទិដ្ឋាការនាំចេញ : -១០% | (+១៦%) | ➢ អាករស្ថានទូត (លិខិតឆ្លងដែននិងទិដ្ឋាការ): -១២% | (-២៧%) |

➥ ***ចំណាយថវិកាជាតិ*** អនុវត្តបានចំនួន ៤៥៩ ពាន់លានរៀល (*មធ្យមប្រចាំខែ ៥៩% នៃគម្រោង*) ក្នុងនោះ **ចំណាយចរន្ត**មានចំនួន ៣៧២ ពាន់លានរៀល (*មធ្យមប្រចាំខែ ៨៨% នៃគម្រោង*) និង**ចំណាយមូលធន**ចំនួន ៨៧ ពាន់លានរៀល។

➥ *បើធៀបនឹងខែមុន* **ចំណាយថវិកាជាតិ** កើនឡើង ៧% និងកើនឡើង ១២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះ ចំណាយចរន្តកើនឡើង ៨% ធៀបនឹងខែមុន និងកើនឡើង ៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ រីឯ**ចំណាយមូលធន** កើនឡើង ៥% ធៀបនឹងខែមុន និងកើនឡើង ៤០% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➥ *ថវិកាជាតិនៃខែតុលាមាន**អតិរេក ១២៤** ពាន់លានរៀល ស្មើនឹង ៣១ លានដុល្លារ ស.រ.អា ។*

## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែតុលា ឆ្នាំ២០១២ មានលក្ខណៈដូចខាងក្រោម៖

➥ រូបិយវត្ថុ $M_2$ មានចំនួន ២៧ ៤៤១ ពាន់លានរៀល កើនឡើង ២,១% ធៀបនឹងខែមុន និងកើនឡើង ២១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➥កំណើនរូបិយវត្ថុ $M_2$ ធៀបនឹងខែមុន បណ្តាលមកពីរូបិយវត្ថុក្រៅធនាគារកើនឡើង 0,៤% ប្រាក់បញ្ញើចរន្តកើនឡើង ១៣% និងប្រាក់បញ្ញើជារូបិយបណ្ណ កើនឡើង ២,៣%។

➥យោងតាមតួលេខសមាសធាតុរូបិយវត្ថុ ក្នុងខែនេះ ប្រាក់រៀលសរុប**នៅក្នុងនិងក្រៅធនាគារ**មានចំនួន ១៧% នៃរូបិយវត្ថុ $M_2$ និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន ៨៣%។

**ក្រាហ្វ៣. សមាសធាតុរូបិយវត្ថុ ខែតុលា ឆ្នាំ ២០១២**



**សមាមាត្រចំនួនប្រាក់រៀល ទៅនឹងរូបិយវត្ថុ $M_2$**

| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុបនៅក្នុង និងក្រៅធនាគារ | ១៩,២% | ១៨,៣% | ១៩,៦% | ១៩,៣% | ១៨,៦% | ១៨% | ១៧% | ១៧% | ១៧% | ១៧% | | |
| ប្រាក់រៀលក្រៅធនាគារ | ១៥,២% | ១៥,២% | ១៥,៣% | ១៤,៨% | ១៤,៧% | ១៤% | ១៤% | ១៤% | ១៣% | ១៣% | | |

**បម្រែបម្រួលសមាសធាតុរូបិយវត្ថុ ក្នុងខែតុលា២០១២: ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន**




- **ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ**មានចំនួន ៣ ២៩៧ លានដុល្លារ កើនឡើង០,៤% ធៀបនឹងខែមុន និងកើនឡើង ១៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** ក្នុងខែនេះមានចំនួន ៩ ៣២៥ ពាន់លានរៀល កើនឡើង ៣% ធៀបនឹងខែមុន និងកើនឡើង ៣១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- ***ការផ្តល់ឥណទានដោយធនាគារពាណិជ្ជ*** មានចំនួន **២១ ៧០៧ ពាន់លានរៀល** កើនឡើង ១,៤% ធៀបនឹងខែមុន និងកើនឡើង ២៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- ***ការផ្តល់ឥណទានដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ*** ក្នុងខែនេះមានចំនួន ៣៤២ ពាន់លានរៀល កើនឡើង ៩,៣% ធៀបនឹងខែមុន និងកើនឡើង ១៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- ***អត្រាការប្រាក់ប្រចាំឆ្នាំ*** នៅធនាគាពាណិជ្ជនាខែតុលា៖

| *ប្រភេទអត្រាការប្រាក់* | *តុលា ២០១២* | *កញ្ញា ២០១២* | *តុលា ២០១១* |
|---|---|---|---|
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | មិនទាន់មានតួលេខ | មិនទាន់មានតួលេខ | ៦,៥២% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | មិនទាន់មានតួលេខ | មិនទាន់មានតួលេខ | ១៩,០៨% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | មិនទាន់មានតួលេខ | មិនទាន់មានតួលេខ | ៤,២៦% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | មិនទាន់មានតួលេខ | មិនទាន់មានតួលេខ | ១៤,៨៦% |

## ៤) ស្ថានភាពកសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➡ក្នុងខែតុលាឆ្នាំ២០១២ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម៖

- **កសិកម្ម៖**
  - ✓ ផលិតផលនេសាទមានចំនួន ៥០ ពាន់តោន កើនឡើង ២៥% ធៀបនឹងខែមុន និងកើនឡើង ១១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- **ឧស្សាហកម្ម៖**
  - ✓ អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ២៧៦,១ GWh ថយចុះ ៦% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ២២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
  - ✓ អគ្គិសនីផ្គត់ផ្គង់ដោយវារីអគ្គិសនីមានចំនួន ៨៩,៩ GWh ថយចុះ ៤១% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង៨២៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

- ✓ ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ៣២១ លានដុល្លារ ថយចុះ ២២% ធៀបនឹងខែមុន និងថយចុះ ២៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- ✓ ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម៖

| ប្រភេទ | ចំនួន —តុលា ២០១២ | ចំនួន—កញ្ញា ២០១២ | ចំនួន—តុលា ២០១១ |
|---|---|---|---|
| ▪ រោងចក្រថ្មី | ២៣ | ៣០ | ៩ |
| ▪ ចំនួនរោងចក្រសរុប | ៨៧០ | ៨៤៧ | ៦៨៨ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ៣០ | ០ | ១៥ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ៤៣ | ០ | ១៦ |

**សម្គាល់** : តួលេខសម្រាប់ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី និងបន្ត) ជាការចុះបញ្ជីនៅក្រសួងឧស្សាហកម្មប៉ុណ្ណោះ។ រោងចក្រ និងឧស្សាហកម្មធុនតូច និងមធ្យមមួយចំនួនដែលបានធ្វើប្រតិភូកម្មឲ្យទៅមន្ទីឧស្សាហកម្មខេត្ត-ក្រុង (ប្រកាស ៦០៧) មិន មានក្នុង តួលេខនេះទេ។ បច្ចុប្បន្នភាពតួលេខនេះ**នឹងត្រូវធ្វើឡើងវិញ**នៅពេលក្រោយ ។

**សំណង់** (ការអនុញ្ញាត)៖

- ✓ សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ៣១៩៣ពាន់ម² ថយចុះ ៦១% ធៀបនឹងខែមុន និងថយចុះ ២៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹងចំនួន ៨៩ លានដុល្លារ ថយចុះ ៧១% ធៀបនឹងខែមុន និងថយចុះ ២០% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន៖

| ប្រភេទ | ពាន់ម² —តុលា ២០១២ | ពាន់ម² —កញ្ញា២០១២ | ពាន់ម² —តុលា ២០១១ |
|---|---|---|---|
| ▪ លំនៅឋាន | ១០០ | ១៧០ | ១៣២ |
| ▪ ឧស្សាហកម្ម | ១៦៦ | ១២៣ | ២៥១ |
| ▪ ពាណិជ្ជកម្ម | ១៥ | ៤៩២ | ៥ |
| ... | | | |
| អនុញ្ញាតសរុប | ៣១៩ | ៨១០ | ៤១២ |

- ✓ សំណង់ដែលពេញនិយមនាខែនេះគឺ ឧស្សាហកម្ម (៥២% នៃផ្ទៃក្រឡាអនុញ្ញាតសរុប) និងសំណង់លំនៅឋាន (៣១% នៃផ្ទៃក្រឡាអនុញ្ញាតសរុប) ។

**ការងារ៖**

| ប្រភេទ | នាក់—តុលា២០១២ | %Δ ធៀបនឹងខែមុន | %Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ការដាក់ពាក្យរកការងារទៅក្រៅប្រទេស | ១៤២៧ | -៦៤% | -៥៩% |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ២៥៦៨ | -៦៣% | -៤៣% |
| អ្នកទទួលបានការងារក្នុងប្រទេស | ១៣៣២ | -៥៦% | -៤០% |
| អ្នកទទួលបានការងារក្រៅប្រទេស | ១២៣៦ | -៦៧% | -៤៧% |

**វិនិយោគ៖**

- ✓ គម្រោងវិនិយោគ**អនុញ្ញាតដោយ** ក.អ.ក. (ថ្មីនិងពង្រីក) ក្នុងខែតុលាមានចំនួន ១៧ គម្រោង ដែលជាទុនវិនិយោគស្មើនឹង ៦៩៧ លានដុល្លារ។ គម្រោងទាំងនេះអាចបង្កើតការងារឲ្យពលករបាន ២២ ពាន់នាក់។

| ប្រភេទ | តុលា២០១២ | កញ្ញា២០១២ | តុលា២០១១ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ៦៩៧ | ៦៤ | ៣៦៣ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ៦ | ៥ | ២ |
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ៤២ (៩) | ៥៩ (១៣) | ១១៦ (១៩) |
| វិស័យទេសចរណ៍ | ៦៤១ | ០ | ២៤៥ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ០ | ០ | ០ |
| ចំនួនគម្រោងថ្មី (ពង្រីក) | ១៦ (១) | ១០ | ១៩ |
| បង្កើតការងារ (ពាន់នាក់) | ២២ | ១១ | ២៤ |

### សេវាកម្ម និងទេសចរណ៍៖

✓ **ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម**

| ប្រភេទ | ចំនួន – តុលា២០១២ | ចំនួន – កញ្ញា២០១២ | ចំនួន–តុលា២០១១ |
|---|---|---|---|
| ▪ ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | | ៣០៦ | ២៨៦ |
| ▪ ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | | ៣ | ៥ |
| ▪ ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | | ១៦៣ | ២១៨ |

✓ **ទំនិញឆ្លងកាត់កំពង់ផែ** (សរុប ៥កំពង់ផែ) មានចំនួន ៤២៨ ពាន់តោន កើនឡើង ៨% ធៀបនឹងខែមុន និងកើនឡើង ៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ៖

| ក្នុងវង់ក្រចកៈ បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន | | | |
|---|---|---|---|
| ▪ កំពង់ផែភ្នំពេញ: +0.៤% | (0) | ▪ កំពង់ផែស្រែអំបិល និងកោះកុង: +៤២% | (–៣៦%) |
| ▪ កំពង់ផែកំពង់សោម: –៦% | (–៧%) | ▪ កំពង់ផែឧកញ៉ាម៉ុង: +៥១% | (+៥៨៨%) |

### ការធ្វើដំណើរតាមផ្លូវអាកាស និងទេសចរណ៍៖

| ប្រភេទ | ចំនួន (ពាន់នាក់) | %Δ ធៀបនឹងខែមុន | %Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ៦,៥ | +៤៧% | +៤៧% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | មិនទាន់មានតួលេខ | | |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | មិនទាន់មានតួលេខ | | |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ៧០ | +៧% | +១០% |
| ចំនួនទេសចរអន្តរជាតិមកដល់ព្រះរាជាណាចក្រកម្ពុជា | ២៩១ | +២០% | +២៥% |
| ✓ តាមផ្លូវអាកាស | ១៤១ | +៣០% | +១៩% |
| ✓ តាមផ្លូវគោក និងទឹក | ១៥០ | +១២% | +៣១% |

## ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

➡ យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ ការនាំចូលនាខែតុលាមានចំនួន ២៥៧០ ពាន់លានរៀល (ស្មើនឹង ៦៣៨ លានដុល្លារ ស.រ.អា.) ថយចុះ ១៥% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ១២% ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ៖

| ទំនិញ | %Δ ធៀបនឹងខែមុន | %Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %Δ ធៀបនឹងខែមុន | %Δ ធៀបខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| រថយន្តសរុប (ព.ល.រ) | +១៣% | +៣៤% | ប្រេងសាំង | –២% | –២% |
| រថយន្តសរុប (គ្រឿង) | +៥% | +២៧% | ប្រេងម៉ាស៊ូត | –១% | +១៥% |
| ម៉ូតូ (គ្រឿង) | +៨% | +៤៩% | ឧស្ម័ន | –២៦% | –១៨% |
| អង្ករ | +១៩% | +១៨៨៥% | ដែកសំណង់ | –២៨% | –៩% |
| ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | –១០% | +១៥៤% | ស៊ីម៉ង់ត៍ | –៥% | +៧០% |
| ជី និងថ្នាំកសិកម្ម | –១០% | +៦៩% | គ្រឿងអេឡិចត្រូនិក | –១៥% | –៥០% |

➡ **ការនាំចេញ** ក្នុងខែតុលា ឆ្នាំ២០១២ មានចំនួន ១៦៧៩ ពាន់លានរៀល ស្មើនឹង ៤១៦ លានដុល្លារ ស.រ.អា. (៦៥% នៃការនាំចូល) ថយចុះ ១១% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ២% ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះមុខទំនិញសំខាន់ៗមាន៖

| ទំនិញ | %Δ ធៀបនឹង ខែមុន | %Δ ធៀបនឹងខែ ដូចគ្នាឆ្នាំមុន | ទំនិញ | %Δ ធៀបនឹង ខែមុន | %Δ ធៀបនឹងខែ ដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ផលិតផលឈើកែច្នៃ | +៥២% | +២៣៨៤% | វាយនភណ្ឌនិងស្បែកជើង | –២២% | –៨% |
| ផលិតផលនេសាទ | –៣៥% | –៥៨% | អង្ករ | +៦៤% | +៣៦% |
| កៅស៊ូ | –៤២% | +៣% | | | |

➡ ក្នុងខែតុលានេះ ជញ្ជីងពាណិជ្ជកម្មមានឱនភាពចំនួន ៨៩១ ពាន់លានរៀល ស្មើនឹង ២២១ លានដុល្លារ ស.រ.អា.។

### ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែតុលា ឆ្នាំ២០១២នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖

| ល.រ. | សូចនាករ | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | អត្រាប្តូរប្រាក់ (ដុល្លារ/រ) | –០៣%, | –១៧%, | សមាមាត្រប្រាក់រៀលធៀបនឹង រូបិយវត្ថុទូទៅ M2 មានកម្រិតទាប។ |
| ២ | ថ្លៃសាច់ជ្រូក | –១៨%, | –១១៥%, | — |
| ៣ | ថ្លៃសាច់គោ | +១៦%, | +១៥% | ការចិញ្ចឹមមានការថយចុះខ្លាំង។ |
| ៤ | ការនាំចេញផលិតផលឈើកែច្នៃ | +៥២% | +២៣៨៤% | — |
| ៥ | ការនាំចូលអង្ករ | +១៩% | +១៨៨៥% | នាំចូលពីវៀតណាម និងនាំចេញបន្តទៅថៃ។ |
| ៦ | ការនាំចេញអង្ករ | +៦៤% | +៣៦% | — |

## ៧. ស្មារតីអង្គប្រជុំ និងការសន្និដ្ឋាន

***អង្គប្រជុំបានពិភាក្សាបញ្ហាសំខាន់ គួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖***

ក) ***ការឡើងថ្លៃនៃប្រាក់រៀល៖*** មានការលើកឡើងថា ប្រាក់រៀលឡើងថ្លៃមានមូលហេតុមួយចំនួនដូចជា រដូវកាលអតិរេកថវិកាជាតិ និងកំណើនប្រាក់បញ្ញើជារៀលនៅក្នុងធនាគារពាណិជ្ជ។ លើសពីនេះទៀត ធនាគារជាតិនៃកម្ពុជាមានគោលនយោបាយថ្មី ដោយអនុញ្ញាតិឲ្យស្ថាប័នមីក្រូហិរញ្ញវត្ថុមួយចំនួនមានសិទ្ធិទទួលប្រាក់បញ្ញើជារៀលពីអ្នកសន្សំ។

ខ) ***បញ្ហាការងារ៖*** មានការខ្វះខាតពលករដើម្បីបម្រើការងារក្នុងស្រុក ដោយសារមានចំណាកស្រុកច្រើន។

គ) ***ការកើនឡើងនៃវិនិយោគ៖*** មួយផ្នែកធំជាការវិនិយោគនៃប្រទេសជប៉ុន។

***សេចក្តីសន្និដ្ឋាន៖***

ក) ការឡើងថ្លៃនៃប្រាក់រៀល ជារួមគឺដោយសារសមាមាត្រនៃប្រាក់រៀលសរុបនៅក្នុងរូបិយវត្ថុទូទៅ M2 មានកម្រិតទាបពេក គឺ១៧% នៃ M2 ប៉ុណ្ណោះ ដែលមិនធ្លាប់មានចាប់តាំពីឆ្នាំ២០០៥ មក (ឆ្នាំ ២០០៥ សូចនាករនេះស្មើនឹង ២៨%)។ រីឯប្រាក់រៀលក្រៅធនាគារមានចំនួនតែ ១៣% នៃ M2 (ឆ្នាំ ២០០៥ សូចនាករនេះស្មើនឹង ២៥%)។ ដូច្នេះក្នុងពេលបច្ចុប្បន្ននេះធនាគារជាតិនៃកម្ពុជា មានលទ្ធភាពបង្កើនសាច់ប្រាក់រៀលនៅក្នុងសេដ្ឋកិច្ច ។

ខ) ដើម្បីដោះស្រាយបញ្ហាខ្វះពលករក្នុងស្រុក គួរមានយុទ្ធសាស្ត្រមួយចំនួនក្នុងទីផ្សារពលកម្ម ដូចជា៖

– ទាក់ទាញពលករដល់មូលដ្ឋាន ខេត្ត-ស្រុក-ឃុំ **ដើម្បីបម្រើការងារក្នុងស្រុក** ដូចដែលបានធ្លាប់ធ្វើដោយក្រុមហ៊ុនឯកជនបរទេស ដែលមានការិយាល័យទទួលចុះឈ្មោះទៅធ្វើការនៅ**ក្រៅប្រទេស**ដូចជា **កូរ៉េ** ថៃ និងម៉ាឡេស៊ីជាដើម។

– ប្រាក់កម្រៃ និងលក្ខខ័ណ្ឌការងារគួរមានកម្រិតសមរម្យ ។

– **បង្កើនការបណ្តុះបណ្តាលវិជ្ជាជីវៈ ។**

# សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែធ្នូ ឆ្នាំ២០១២

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០២/១២/១២<br>ម៉ោង ០៧:៣០ នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីមិទ្ទិញអបអរសាទរខួបអនុស្សាវរីយ៍លើកទី ៣៤ ទិវាកំណើតរណសិរ្សសាមគ្គី អភិវឌ្ឍន៍មាតុភូមិកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងជាប្រធានក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គី អភិវឌ្ឍន៍មាតុភូមិកម្ពុជា នៅសាលសន្និសីទចតុមុខ។ |
| ២ | ០៣/១២/១២<br>ម៉ោង ០៧:៣០ នាទី | ចូលរួមជាកិត្តិយស ក្នុងទិវាជនពិការកម្ពុជាលើកទី ១៤ និងជនពិការអន្តរជាតិលើកទី ៣០ និងពិធីបើកសិក្ខាសាលាស្តីពីការដាក់បញ្ចូលពិការភាពក្នុងការអភិវឌ្ឍ ការផ្សព្វផ្សាយរបាយការណ៍ពិភពលោកស្តីពី ពិការភាព និងអនុសញ្ញាស្តីពីសិទ្ធិជនពិការ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនា បតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅសាលមហោស្រពកោះពេជ្រ។ |
| ៣ | ០៣/១២/១២<br>ម៉ោង ១៦:០០ នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា ៩ និងមាត្រា ១០ នៃច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។<br>២-សេចក្តីព្រាងគោលនយោបាយធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ។<br>៣-សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិវាយតម្លៃសេវាសាធារណៈ។<br>៤-សេចក្តីព្រាងអនុក្រឹត្យស្តីពីបែបបទ និងនីតិវិធី នៃការដាក់ឈ្មោះផ្លូវ ឬលេខផ្លូវ និងការកែប្រែ ឈ្មោះផ្លូវ និងលេខផ្លូវ។<br>៥-បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ០៤/១២/១២<br>ម៉ោង ០៩:០០ នាទី | ដឹកនាំគណៈកម្មការសាងសង់ ចុះពិនិត្យទីតាំងសម្រាប់សាងសង់អគារអង្គរក្សចំនួន ១០០ នាក់ នៅក្នុងបរិវេណទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ០៦/១២/១២<br>ម៉ោង ១៦:០០ នាទី | ចូលរួមក្នុងពិធីបិទកិច្ចប្រជុំពេញអង្គលើកទី ១៩ របស់គណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍតំបន់ប្រវត្តិសាស្ត្រអង្គរ (CIC-Angkor) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរអប្សរា នៅខេត្តសៀមរាប។ |
| ៦ | ១០/១២/១២<br>ម៉ោង ០៧ : ៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបើកការដ្ឋានសាងសង់ផ្សារទំនើប អ៊ីអន ម៉ល ភ្នំពេញ “AEON MALL Phnom Penh” របស់ក្រុមហ៊ុន អ៊ីអន ម៉ល (ខេមបូឌា) ខូ អិលធីឌី “AEON MALL (Cambodia) Co., Ltd” ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។ |

# សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែធ្នូ ឆ្នាំ២០១២ (ត)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៧ | ១០/១២/១២ ម៉ោង ១៨ : ០០នាទី | ចូលរួមក្នុងពិធីនៃពានរង្វាន់ណូបែលសន្តិភាព (Nobel Peace Prize) និងទិវាសិទ្ធិមនុស្ស នៅ European Union Delegation ។ |
| ៨ | ១១/១២/១២ ម៉ោង ០៨ : ៣០នាទី | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែតុលា ឆ្នាំ២០១២ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៩ | ១២/១២/១២ ម៉ោង ០៧ : ៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធអគារទីស្តីការក្រសួង និងបើកសន្និបាតបូកសរុបការងារអាណត្តិនៃការអនុវត្តផែនការសកម្មភាព ៤ឆ្នាំ (២០០៩-២០១២) និងទិសដៅអនុវត្តបន្ត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ |
| ១០ | ១២/១២/១២ ម៉ោង ១៨ : ០០នាទី | ចូលរួមក្នុងពិធីខួបកំណើតព្រះចៅ នៃប្រទេសជប៉ុន នៅស្ថានទូតជប៉ុន។ |
| ១១ | ១៣/១២/១២ ម៉ោង ០៧ : ៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងប្រគល់ប័ណ្ណ "អាហារូបករណ៍ សម្តេចតេជោ **ហ៊ុន សែន ហាន់ជា** ចក្ខុវិស័យ ១០០ ឆ្នាំ ២០១២" ជូនដល់និស្សិត សាកលវិទ្យាល័យកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅវិទ្យាស្ថានជាតិអប់រំ។ |
| ១២ | ១៣/១២/១២ ម៉ោង ១៨ : ៣០នាទី | ចូលរួមជាកិត្តិយសក្នុងរាត្រីស្រមោលស ២០១២ នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា។ |
| ១៣ | ១៤/១២/១២ ម៉ោង ០៨ : ៣០នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីការបង្ការ និងការពន្លត់អគ្គីភ័យ។<br>២-សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ។<br>៣-សេចក្តីព្រាងអនុក្រឹត្យស្តីពីនីតិវិធី នៃការបង្កើត ការរំលាយចោល និងការកំណត់តួនាទី និងភារកិច្ច នៃសហគមន៍កសិករប្រើប្រាស់ទឹក។<br>៤-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីកន្លាស់រូបសញ្ញា សញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រីជាន់ខ្ពស់សវន កម្ម នៃអាជ្ញាធរសវនកម្មជាតិ។<br>៥-បញ្ហាផ្សេងៗ។ នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ១៤ | ១៧/១២/១២ ម៉ោង ០៩ : ០០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយ លោក **មី សារ៉ែម** ប្រធានក្រុមហ៊ុន DPCHT នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |

# សកម្មភាពដទៃទៀតរបស់ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែធ្នូ ឆ្នាំ២០១២ (ត)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៥ | **១៧/១២/១២** **ម៉ោង ១៥ : ៣០នាទី** | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖ ១-សេចក្តីព្រាងច្បាប់ស្តីពីសហគមន៍កសិកម្ម។ ២-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន និងសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីអភិវឌ្ឍយុវជន។ ៣-សេចក្តីព្រាងអនុក្រឹត្យស្តីពីក្រុមសីលធម៌ឆ្មប។ ៤-បញ្ហាផ្សេងៗ។ ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៦ | **១៨/១២/១២** **ម៉ោង ០៨ : ០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីបើកសន្និសីទ នៃអង្គការសហព័ន្ធវិស្វកម្មអាស៊ានលើកទី ៣០ (CAFEO-30) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាគណៈវិស្វករកម្ពុជា នៅសណ្ឋាគារសូហ្វីតែល ភ្នំពេញភូគីត្រា។ |
| ១៧ | **១៨/១២/១២** **ម៉ោង ១០ : ៣០នាទី** | ចូលរួមប្រជុំក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនសិប្បករអង្គរ (Artisan Angkor) នៅរាជធានីភ្នំពេញ។ |
| ១៨ | **១៩/១២/១២** **ម៉ោង ០៨ : ៣០នាទី** | ជាអធិបតីភាព ក្នុងសិក្ខាសាលាស្តីពីបន្ទុកចំណាយលើបញ្ញត្តិកម្ម (Cost Regulation) របស់គម្រោងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត នៅសណ្ឋាគារភ្នំពេញ។ |
| ១៩ | **២០/១២/១២** **ម៉ោង ០៩ : ០០នាទី** | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖ ១-សេចក្តីព្រាងច្បាប់ស្តីពីសហគមន៍កសិកម្ម។ ២-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន និងសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីអភិវឌ្ឍយុវជន។ ៣-សេចក្តីព្រាងអនុក្រឹត្យស្តីពីក្រុមសីលធម៌ឆ្មប។ ៤-បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២០ | **២០/១២/១២** **ម៉ោង ១៥ : ៣០នាទី** | ចូលរួមប្រជុំគណៈកម្មការព្រលានយន្តហោះ នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |
| ២១ | **២១/១២/១២** **ម៉ោង ១៥ : ៣០នាទី** | ជួបប្រជុំពិភាក្សាការងារជាមួយ ក្រុមការងារគណៈកម្មការព្រលានយន្តហោះ នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |

# សកម្មភាពដទៃទៀតរបស់ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែធ្នូ ឆ្នាំ២០១២ (តចប់)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ២២ | ២២/១២/១២ ម៉ោង ០៩ : ៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធហាង អិលជី (LG) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅមហាវិថីព្រះមុនីវង្ស សង្កាត់ផ្សារថ្មី ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ |
| ២៣ | ២៤/១២/១២ ម៉ោង ១៥ : ៣០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយ ឯកឧត្តម **យឹម ណុលសន** និងលោក **ម៉ក់ ឆារ៉ា** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២៤ | ២៤/១២/១២ ម៉ោង ១៧ : ០០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយ ឯកឧត្តម **ផេង សុវិជ្ជានោ** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២៥ | ២៥/១២/១២ ម៉ោង ០៧ : ៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធដាក់ឲ្យដំណើរការជាផ្លូវការនូវរោងចក្រផលិតជីកសិកម្មរបស់ក្រុមហ៊ុន Five Star International Fertilizer Cambodia Co., Ltd ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិ ព្រឹទ្ធបណ្ឌិត នៅឃុំសំរោងធំ ស្រុកគៀនស្វាយ ខេត្តកណ្តាល ។ |
| ២៦ | ២៦/១២/១២ ម៉ោង ០៩ : ០០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយ លោក MAS តំណាងស្ថានទូតប្រទេសបារាំង ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២៧ | ២៨/១២/១២ ម៉ោង ០៨ : ៣០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការសាងសង់ ដើម្បីពិនិត្យលើការស្នើសុំពន្យាពេលសាងសង់អគារលក់សំបុត្រពេលថ្ងៃ រយៈពេល ០៣ខែ គឺចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៣ របស់ក្រុមហ៊ុន ហ្គេនធីង ធីមវើក នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២៨ | ២៨/១២/១២ ម៉ោង ០៩ : ៣០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខាលើការផ្តល់អាជ្ញាបណ្ណ រោងចក្រចម្រាញ់ប្រេងកាត និងកិច្ចសន្យាសាងសង់រោងចក្រចម្រាញ់ប្រេងកាត រវាងអាជ្ញាធរប្រេងកាតជាតិកម្ពុជា ជាមួយក្រុមហ៊ុន ខេមបូ ឌាន ភេត្រូខេមីខល ខូអិលធីឌី និងក្រុមហ៊ុន ខេមបូឌាន ភេត្រូខេមីខល ខូអិលធីឌី ជាមួយក្រុមហ៊ុន SINOMACHCHIN PERFECT MACHINERY INDUSTRY CORP.LTD ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២៩ | ២៨/១២/១២ ម៉ោង ១៧ : ០០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីសំណេះសំណាលជាមួយមន្ត្រីរាជការ នៃទីស្តីការគណៈរដ្ឋមន្ត្រី និងពិធីជប់ លៀងឆ្លងឆ្នាំសកល ឆ្នាំ២០១២-២០១៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣០ | ៣០/១២/១២ ម៉ោង ០៨ : ៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីចែកបណ្ណកម្មសិទ្ធជូនប្រជាពលរដ្ឋ ក្នុងឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ។ |

# សកម្មភាពដទៃទៀតរបស់ ឯកឧត្តម អនុប្រធាន ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែធ្នូ ឆ្នាំ២០១២

## ឯកឧត្តម យឹម ណុលសន អនុប្រធាន

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ១៥/១២/១២ ម៉ោង ០៩ : ០០ នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវផ្លូវវាងកូរ៉េជំហានទី២ ប្រវែង ២០,៥គីឡូម៉ែត្រ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅបរិវេណវិទ្យាល័យបន្ទាយស្រី ឃុំប្រដាក ស្រុកបន្ទាយស្រី ខេត្តសៀមរាប។ |
| ២ | ១៨/១២/១២ ម៉ោង ០៨ : ០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបើកសន្និសីទ នៃអង្គការសហព័ន្ធវិស្វកម្មអាស៊ានលើកទី ៣០ (CAFEO-30) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាគណៈវិស្វករកម្ពុជា នៅសណ្ឋាគារសូហ្វីតែល ភ្នំពេញភូគីត្រា។ |
| ៣ | ១៨/១២/១២ ម៉ោង ១០ : ៣០នាទី | ចូលរួមប្រជុំក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនសិប្បករអង្គរ (Artisan Angkor) នៅរាជធានីភ្នំពេញ។ |
| ៤ | ១៩/១២/១២ ម៉ោង ០៨ : ៣០នាទី | ចូលរួមជាកិត្តិយស ក្នុងសិក្ខាសាលាស្តីពីបន្ទុកចំណាយលើបញ្ញត្តិកម្ម (Cost Regulation) របស់គម្រោងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត នៅសណ្ឋាគារភ្នំពេញ។ |
| ៥ | ២១/១២/១២ ម៉ោង ១៤ : ៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់មេដាយរបស់ស្ថាប័នសវនកម្មរដ្ឋវៀតណាម ជូនដល់ឯកឧត្តម អ៊ិត ឈន សមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅអង្គភាពប្រឆាំងអំពើពុករលួយ។ |

## ឯកឧត្តម យឹម ណុលសន អនុប្រធាន

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ២១/១២/១២ ម៉ោង ១៤ : ៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់មេដាយរបស់ស្ថាប័នសវនកម្មរដ្ឋវៀតណាម ជូនដល់ឯកឧត្តម អ៊ិត ឈន សមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅអង្គភាពប្រឆាំងអំពើពុករលួយ។ |
| ២ | ២២/១២/១២ ម៉ោង ០៩ : ៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធហាង អិលជី (LG) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅមហាវិថីព្រះមុនីវង្ស សង្កាត់ផ្សារថ្មី ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ |

# សកម្មភាពដទៃទៀតរបស់ ឯកឧត្តម អគ្គលេខាធិការ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែធ្នូ ឆ្នាំ២០១២

## ឯកឧត្តម ខ៉ាន់ តិរុណា អគ្គលេខាធិការ

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ១៤/១២/១២<br>ម៉ោង ០៨ : ៣០នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីការបង្ការ និងការពន្លត់អគ្គីភ័យ។<br>២-សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ។<br>៣-សេចក្តីព្រាងអនុក្រឹត្យស្តីពីនីតិវិធី នៃការបង្កើត ការរំលាយចោល និងការកំណត់តួនាទី និងភារកិច្ច នៃសហគមន៍កសិករប្រើប្រាស់ទឹក។<br>៤-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីកន្លាស់រូបសញ្ញា សញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រីជាន់ខ្ពស់សវន កម្ម នៃអាជ្ញាធរសវនកម្មជាតិ។<br>៥-បញ្ហាផ្សេងៗ។<br>នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ២ | ១៥/១២/១២<br>ម៉ោង ០៩ : ០០ នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវផ្លូវវាងក្រវ៉េជំហានទី២ ប្រវែង ២០,៥គីឡូម៉ែត្រ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅបរិវេណវិទ្យាល័យបន្ទាយស្រី ឃុំប្រដាក ស្រុកបន្ទាយស្រី ខេត្តសៀមរាប។ |
| ៣ | ១៨/១២/១២<br>ម៉ោង ០៨ : ០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបើកសន្និសីទ នៃអង្គការសហព័ន្ធវិស្វកម្មអាស៊ានលើកទី ៣០ (CAFEO-30) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាគណៈវិស្វករកម្ពុជា នៅសណ្ឋាគារសូហ្វីតែល ភ្នំពេញភូគីត្រា។ |
| ៤ | ២១/១២/១២<br>ម៉ោង ០៩: ០០នាទី | ចូលរួមក្នុងកិច្ចប្រជុំក្រុមជនបង្គោលប្រឆាំងអំពើពុករលួយ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ២២/១២/១២<br>ម៉ោង ០៩ : ៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធហាង អិលជី (LG) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅមហាវិថីព្រះមុនីវង្ស សង្កាត់ផ្សារថ្មី ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ |

# ព្រឹត្តិបត្រព័ត៌មាន

| | | |
|---|---|---|
| នាយកគ្រប់គ្រងទូទៅ: | **ឯកឧត្តម គីម សយសាម៉ាឡៃន** | អនុប្រធាន ក.ស.វ. |
| និពន្ធនាយក: | **ឯកឧត្តម ខ៊ាន់ តិរុណា** | អគ្គលេខាធិការ ក.ស.វ. |
| និពន្ធអគ្គបទ: | **ឯកឧត្តម អេង រត្នមុនី** | អគ្គលេខាធិការរង ក.ស.វ. |
| វិភាគស្ថានភាពសេដ្ឋកិច្ច: | **ឯកឧត្តម ម៉ម សារិទ្ធ** | សមាជិកបម្រុង ក.ស.វ. |
| ទំនាក់ទំនងនិងបោះពុម្ពផ្សាយ: | **លោក ម៉ក់ ឆារ៉ា** | ប្រធានផ្នែក ក.ស.វ. |
| បច្ចេកទេសកុំព្យូទ័រនិងសម្របសម្រួល: | **លោក សយ វាស្នា** | អនុប្រធានផ្នែក ក.ស.វ. |
| យកព័ត៌មាននិងថតរូប: | **លោក មុត ភក្កដា** | មន្ត្រី ក.ស.វ. |



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in